I05228

25

ចម្លើយរបស់ឈ្មោះចាន់.ទៀង

នាទី អនុក្រុម

អង្គភាព៣៦.ត៣១៦ក.៣៣១០

ចូលពេស៊ីហារ ខែ១៨ ឆ្នាំ៧៦

**អំពីខ្សែរបក្សពួកសេ៊ីអ៊ាដែលធ្វើ**
**សកម្មភាពប្រឆាំងបដិវត្តន៍ -**

ខ្សែរលើរបស់ ឡុង

១.ឈ្មោះ លីន នាទី ន.ប វ.៥២២ ក.៣៣១០ បច្ចុប្បន្នអ.កចាប់ ។

២. ខ្សែរស្មើរគឺរូបខ្ញុំ

ខ្សែរក្រោមរបស់ លីន

៣.ឈ្មោះ គៀ នាទី យុទ្ធជន វ.៥២២ ក.៣៣១០ បច្ចុប្បន្ននៅ៣១៧ ។

៤.ឈ្មោះសោរទឿននាទី មេពួក វ.៥២២ ក.៣៣១១ បច្ចុប្បន្ននៅ៣១៦ ។

៥.ឈ្មោះ ភាត នាទី យុទ្ធជន វ.៥២២ ក.៣៣១០ បច្ចុប្បន្ននៅ៣១៦ ។

៦.ឈ្មោះ រុន នាទី មេក្រុម វ.៥២២ ក.៣៣១០ បច្ចុប្បន្នក្ដាប់មិនបាន។

៧.ឈ្មោះ ហេង នាទី យ.ធក.៥វ.៥២២ ក.៣៣១០ បច្ចុប្បន្នក្ដាប់មិនបាន។

៨.ឈ្មោះ រិន នាទី មេក្រុម វ.៥២២ ក.៣៣១០ បច្ចុប្បន្នក្ដាប់មិនបាន។

៩.ឈ្មោះ ភាព នាទី ន.បក.៥វ.៥២២ ក.៣៣១០ បច្ចុប្បន្ននៅ៣១៧ ។

១០.ឈ្មោះ បួរ នាទី ន.បក.៥វ.៥២២ ក.៣៣១០ បច្ចុប្បន្នក្ដាប់មិនបាន។

១១.ឈ្មោះ ចេង នាទី ន.បក.៥វ.៥២២ ក.៣៣១០ បច្ចុប្បន្ននៅ៣១៧ ។

១២. ឈ្មោះ យឿន នាទី មេក្រុម វ.ត២២ ក.ព៣១០ បច្ចុប្បន្ននៅ៣១៧ ។

១៣. ឈ្មោះ ភាត់ នាទី មេក្រុម វ.ត២២ ក.ព៣១០ បច្ចុប្បន្នក្ដាប់ពុំបាន ។

១៤. ឈ្មោះ ឈុខ នាទី យុទ្ធជន វ.ធំ១២ ក.ព៣១០ បច្ចុប្បន្ននៅ៣១៧ ។

១៥. ឈ្មោះ ទីរ៉ម នាទី យុទ្ធជន វ.ធំ១២ ក.ព៣១០ បច្ចុប្បន្ននៅ៣១៦ ។

១៦. ឈ្មោះ ឯម នាទី មេក្រុម វ.ធំ១២ ក.ព៣១០ បច្ចុប្បន្ននៅ៣១៧ ។

១៧. ឈ្មោះ ឈិន នាទី មេពួក វ.ត២២ ក.ព៣១០ បច្ចុប្បន្ននៅ៣១៦ ។

១៨. ឈ្មោះ ថា នាទី យុទ្ធជន វ.ត២២ ក.ព៣១០ បច្ចុប្បន្ននៅ៣១៦ ។

១៩. ឈ្មោះ ឈឹម នាទី យុទ្ធជន វ.ត២២ ក.ព៣១០ បច្ចុប្បន្ននៅ៣១៦ ។

២០. ឈ្មោះ ខាត់ នាទី មេក្រុម វ.ធំ១២ពិកា ក.ព៣១០បច្ចុប្បន្ននៅ៣១៦ ។

៣

**អត្ថបទប្រវត្តិលក្ខភាពរបស់ខ្ញុំឈ្មោះ**
**ចាន់.ឡេង តាំងពីកើតរហូតដល់ថ្ងៃ**
**ចូលធ្វើបដិវត្តន៍**

- យើងខ្ញុំឈ្មោះ ចាន់ ឡេង អាយុ ៤០ ឆ្នាំ មានគ្រួសាររហើយ មានកំណើតកើតនៅភូមិ ឫស្សីព្រៃ ឃុំទុំរីង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ. ឪពុកឈ្មោះ ចាន់ អាយុ ៦០ ឆ្នាំ "នៅរស់" ម្តាយឈ្មោះ ហៀម អាយុមិនដឹង "ស្លាប់" ខ្ញុំមានបងប្អូន ៥ នាក់ ប្រុស ៤ នាក់ ស្រី ១ នាក់ ចូលធ្វើបដិវត្តន៍៣នាក់ នៅសហករណ៍ ២ នាក់ ។ ចំពោះរូបខ្ញុំតាំងពីដឹងក្តីការណាមក គឺរស់នៅជាមួយជីតារបស់ខ្ញុំ ដោយម្តាយរបស់ខ្ញុំស្លាប់ចោលខ្ញុំតាំងពីខ្ញុំនៅមិនទាន់ដឹងក្តីម្ល៉េះ ឯចំពោះឪពុករបស់ខ្ញុំគាត់ចេញទៅស៊ីឈ្នួលគេបាត់រហូតគាត់មានប្រពន្ធមួយទៀត ទើបគាត់ត្រឡប់មកភូមិកំណើតវិញ ហើយខ្ញុំក៏សុំជីតារបស់ខ្ញុំមកនៅជាមួយឪពុកខ្ញុំវិញ រយៈដែលខ្ញុំមកនៅជាមួយឪពុករបស់ខ្ញុំវិញនោះ គឺខ្ញុំមានអាយុ ១៣ ឆ្នាំហើយ ពេលនោះខ្ញុំក៏បានជួយធ្វើការងារជាមួយឪពុកហើយនិងម្តាយចុងរបស់ខ្ញុំ រហូតដល់ខ្ញុំមានអាយុ ១៨ ឆ្នាំខ្ញុំក៏មានការលួចស្រលាញ់នារី ២ នាក់ដោយបានខូចសីលធម៌ជាមួយផង បានប្រហែលមួយឆ្នាំ ក្រោយមកត្រូវនិងខ្ញុំអាយុ ១៩ ឆ្នាំឪពុករបស់ខ្ញុំគាត់ក៏រកគ្រួសារ

ឲ្យខ្ញុំតែម្តង ក្រោយពីខ្ញុំមានគ្រួសារហើយ ខ្ញុំក៏បែកចេញពីឪពុកម្តាយរបស់ខ្ញុំ គឺខ្ញុំមករកស៊ីជាមួយគ្រួសាររបស់ខ្ញុំវិញ ដោយប្រកបមុខរបរធ្វើស្រែ ហើយនិងដើររើសអីវ ដើរបោចវល្លិ ចញ្ចឹមគ្រួសាររបស់ខ្ញុំ រហូតមកដល់ខ្ញុំមានអាយុ ៣៣ ឆ្នាំត្រូវនិងឆ្នាំ ១៩៧០ អង្គការក៏បានចាត់តាំងរូបខ្ញុំឲ្យទទួលនាទី ជាប្រធានភូមិ ឫស្សីស្រែ រយៈដែលខ្ញុំធ្វើប្រធានភូមិនោះ គឺមិនដែលមានបញ្ហាអ្វីដែលទំនាស់ជាមួយប្រជាជនទេ គឺគ្រាន់តែមានពាក្យសំដីធំតូច ដាក់អ្នកណាដែលមិនទៅធ្វើការងាររួម ចង់ធ្វើការងារផ្ទាល់ខ្លួន រហូតមកដល់ថ្ងៃទី ២៥.៨.៧៣ ទើបអង្គការបានដកនាទីខ្ញុំពីប្រធានភូមិឲ្យចូលធ្វើបដិវត្តន៍ ។

o

o o

៥



អត្ថបទប្រវត្តិរូបកម្មភាពក្រោយចូល
បដិវត្តន៍រហូតដល់ថ្ងៃអង្គការចាប់
ខ្លួនខ្ញុំតែម្តង

-មុនដំបូងខ្ញុំចូលធ្វើបដិវត្តន៍នៅភូមិ ខុស សង្កាត់ ទូរីន ស្រុក សណ្ដាន់ ខេត្ត កំពង់ធំ ឈ្មោះ ខាន់ ជាអ្នកនាំចូល នាទីគាត់ លេខាសង្កាត់ ក្រោយពីចូលបដិវត្តន៍រួចខ្ញុំក៏បានរស់នៅមន្ទីរសង្កាត់បានមួយថ្ងៃក៏ឈ្មោះ ខាន់ ចាត់តាំងរូបខ្ញុំអោយមកនៅយោធា ស្រុក សណ្ដាន់ ពេលនោះខ្ញុំរស់នៅមន្ទីរស្រុកបានប្រហែលបីថ្ងៃ ក្នុងនោះមានឈ្មោះ អ៊ុន ជាអ្នកទទួលខុសត្រូវ នាទីលេខាស្រុក បច្ចុប្បន្នភាពមិនបាន ក្រោយពីបានរស់នៅមន្ទីរស្រុកនេះបានបីថ្ងៃឈ្មោះ អ៊ុន ក៏បានចាត់តាំងរូបខ្ញុំហើយមិត្តយើងមួយចំនួនទៀត អោយមកចូលនៅក្នុងអង្គភាពវរៈសេនាតូច ៥០២ មានឈ្មោះ យុន ជាអ្នកទទួលខុសត្រូវ ក្រោយខ្ញុំចូលមកនៅអង្គភាពវរៈសេនាតូចនេះបានប្រហែលមួយថ្ងៃ អង្គការក៏បានចាត់តាំងរូបខ្ញុំអោយចូលវាយខ្មាំងនៅសមរភូមិកំពង់ចាមអស់រយៈបី ខែ នៅពេលនោះខ្ញុំវាយខ្មាំងមិនទាន់ផ្ដាច់ខាត ក៏ភ័យខ្លាចរហូតរត់ចោល ខែ១ ត្រៀម រត់រហូតទៅដល់ផ្ទះប្រាប់ទីតឈ្មោះ ឈួន នៅ ខ្ញុំវិលមក

អង្គភាពនៅខ្សែត្រៀមវិញ    ពេលខ្ញុំមកដល់សមរភូមិវិញគឺខ្ញុំចូលខ្សែត្រៀមតែម្តងទៀត    ពេលនោះខ្មាំងនិងវាយសំរុកយ៉ាងខ្លាំងមកលើខ្សែត្រៀមធ្វើអោយបាក់ខ្សែត្រៀម    រហូតខ្មាំងយកខ្សែត្រៀមនោះបានតែម្តង    បន្ទាប់ពីវាយនៅសមរភូមិកំពង់ចាមមិនដាច់    នៅចុងឆ្នាំ ៧៣ អង្គការក៏បានដកអង្គភាពនេះពីសមរភូមិកំពង់ចាម    មកសមរភូមិវាលវង្សវិញអស់រយៈបីខែ    ក៏ផ្លាស់ពីនោះមកសមរភូមិសៀមរាប    នៅដើមឆ្នាំ ១៩៧៤    ក្រោយពីវាយសមរភូមិសៀមរាបនោះហើយ    អង្គការក៏ដកអង្គភាពនេះអោយមកវាយខ្មាំងនៅសមរភូមិកំពង់ចាមវិញ    រយៈក្រោយមកអង្គការក៏បានចាត់តាំងអង្គភាពនេះអោយនៅប្រចាំការនៅសមរភូមិកំពង់ចាមនេះរហូតមកដល់ខែ៩.៧៤    ខ្ញុំក៏សុំអ្នកទទួលខុសត្រូវទៅលេងផ្ទះ    ពេលខ្ញុំទៅដល់ផ្ទះភ្លាមខ្ញុំក៏បានជម្ងឺ    រហូតមកដល់ជម្ងឺជា    ខ្ញុំមិនត្រឡប់មកអង្គភាពរបស់ខ្ញុំរស់នៅវិញទេ    រហូតមានឈ្មោះ រ៉ន គាត់ទៅហៅខ្ញុំអោយមកនៅអង្គភាពវិញ    តែពេលនោះគឺខ្ញុំមិនបានវិលមកអង្គភាពចាស់វិញទេ គឺខ្ញុំទៅអង្គភាពវរៈសេនាតូច ១២ វិញ    ក្នុងនោះមានឈ្មោះ ផុន.ស៊ុម ឈ្មោះ វែន    ជាអ្នកទទួលខុសត្រូវ បច្ចុប្បន្នអង្គការចាប់អស់ហើយ ។

<u>បញ្ជាក់</u> : ចំពោះរូបខ្ញុំរស់នៅតាមដំណាក់កាលនិមួយៗគឺគ្មាន

ឈ្មោះណាឡាក់មកអប់រំរូបខ្ញុំអោយក្បត់ពីបដិវត្តន៍ទេ ។ ក្រោយពីខ្ញុំមកនៅអង្គភាពវរៈសេនាតូច ១២ នេះគឺអង្គភាពនេះត្រូវមានភារៈកិច្ចធ្វើស្រែនៅស្រុកបារាយ ខ្ញុំនៅធ្វើស្រែនៅស្រុកបារាយបានប្រហែល១ខែកន្លះ អង្គការក៏បានដកអង្គភាពនេះអោយមកធ្វើស្រែនៅដីវាំងវិញ ក្រោយពីបានមកនៅធ្វើស្រែនៅដីវាំងនេះបានប្រហែល ២ ខែកន្លះត្រូវនិងដើមឆ្នាំ ១៩៧៦ អង្គការក៏ចាត់តាំងអង្គភាពនោះអោយមកនៅភូមិពទឹត ដោយមានភារៈកិច្ចធ្វើត្រូវបានប្រហែលកន្លះខែក៏ត្រឡប់មកភ្នំពេញវិញ បានមួយខែ ត្រូវនិងខែ ៥.៧៦ អង្គការក៏បានរំលាយវរៈសេនាតូច១២នេះ ហើយចាត់តាំងវរៈសេនាតូចថ្មី តែដោយឡែករូបខ្ញុំក៏បានទៅនៅអង្គភាពវរៈសេនាតូច ២២ វរៈសេនាធំ ១២ កងពល៣១០ ក្នុងនោះមានឈ្មោះលីន ឈ្មោះ សា នឿន ហើយនិងឈ្មោះ ស្រួយ ជាអ្នកទទួលខុសត្រូវបច្ចុប្បន្នអង្គការចាប់អស់ហើយ ។ ក្រោយពីបានរៀបចំអង្គភាពរួចហើយអង្គការក៏បានចាត់តាំងអង្គភាពនេះអោយទៅធ្វើស្រែ នៅប្រឡាយធំ ហើយរយៈដែលខ្ញុំធ្វើស្រែប្រឡាយធំនេះ គឺខ្ញុំធ្វើការងារជាធម្មតារហូតមកដល់ខែ៨.៧៦ ទើបមានឈ្មោះ លីន មកអប់រំយើងខ្ញុំអោយក្បត់ពីបដិវត្តន៍តែម្តង ។ មុនដំបូងគាត់តែងតែមានមនោសញ្ចេតនាមកលើរូបខ្ញុំ ហើយគាត់ចេះតែលេងសើចពីនេះពីនោះធ្វើអោយខ្ញុំទុកចិត្តគាត់ ហើយគាត់ក៏ក្តាប់បានខ្លួន

គោលជំហររបស់ខ្ញុំដាច់ គាត់ក៏ចាប់ផ្ដើមនិយាយអួតទាញគោលជំហររបស់ខ្ញុំ ហើយគាត់និយាយអំពីហេតុផលលំបាកស្រួលរបស់បដិវត្តន៍ថា បដិវត្តន៍សង្គមនិយមធ្វើការងារតែក្ដៅណាស់ហើយមិនស្រាប់ស្រាន់ទៀត បើសង្គមថ្មីមួយទៀតវិញគឺមានលុយចាយ ហើយស្រួលគ្នាធ្វើការងារដូចបដិវត្តន៍ទេ ស៊ីចុកស្រប់ស្រាន់ដែរ ក្រោយពីគាត់និយាយដូចខាងលើនេះហើយខ្ញុំក៏មានសតិអារម្មណ៍គោលជំហរឯកភាពតាមគាត់ទាំងស្រុង ទន្ទឹមនឹងនេះខ្ញុំមានសតិអារម្មណ៍កំរើកប្រឆាំងបដិវត្តន៍ជាបន្តបន្ទាប់ដែរ រហូតមកដល់ចុងខែ១៨ ឆ្នាំ ១៩៧៦ . ឈ្មោះ ស៊ីន បានហៅរូបខ្ញុំទៅកន្លែងផ្ទះ ស៊ីន នៅប្រឡាយធំ ពេលទៅដល់ភ្លាម ស៊ីន ក៏ចាប់ផ្ដើមបើកអង្គប្រជុំ ដោយ ស៊ីនបានទទួលតាមរូបខ្ញុំអោយចូលជាសមាជិកសេ.អ៊ី.អា មួយរូបតែម្ដង កម្មវិធីចាប់ផ្ដើមពីម៉ោង៧ដល់ម៉ោង៨ទើបចប់ ពេលបញ្ចូលនេះគឺមិនបានគោរពទង់ទេ គឺស្រាន់ ស៊ីន . បង្ហាញអោយរូបខ្ញុំឃើញប៉ុណ្ណោះ ឯលញ្ញាទង់គឺមានរូបផ្កាយបីមានពណ៌ក្រហម ក្រោយពី ស៊ីន ទទួលនាមរួចហើយ ស៊ីនក៏បានប្រកាសប្រាប់ឈ្មោះសេអ៊ីអាចាស់ដើម្បីអោយធ្វើការទាក់ទងគ្នាក្នុងការធ្វើសកម្មភាពប្រឆាំងបដិវត្តន៍មានឈ្មោះ គៀវ.ឈារឿន.អាត.រុន.ហេង.វិន.ភាព.បូរ.ថាង.យឿន.ភាន់.សុខ.វ៉េម.ឯម.ល៊ិន.ថា.ស៊ីម.ខាត់ ៗ

- ក្រោយពី ស៊ីន ប្រកាសប្រាប់ឈ្មោះរួចហើយ ស៊ីន ក៏បានធ្វើការណែនាំ

ហើយពន្យល់ទិសដៅរបស់សេរីភាពដែលត្រូវអនុវត្តន៍ទៅថ្ងៃមុខគឺ ត្រូវធ្វើសកម្មភាពបំផ្លាញផលបដិវត្តន៍ ហើយនិងបំផុសមិត្តយើងនៅក្នុងអង្គភាព ដែលដោយឡែកយើងត្រូវមើលអ្នកណាដែលមានគោលជំហរមិនរឹងប៉ឹងខាងបដិវត្តន៍ ហើយត្រូវលាក់ការអោយជិតប្រយ័ត្នបែកការ បន្ទាប់មក លីន បានបន្ថែមដោយសំបុងក្រោយទៀតថា យើងធ្វើសកម្មភាពនេះគឺយើងដោយបំពានខ្លះ ហើយនិងធ្វើដោយស្របច្បាប់ខ្លះ ដើម្បីធ្វើយ៉ាងណាកុំអោយគេចាប់អារម្មណ៍មកលើយើង បន្ទាប់ពីសិក្សាបានដំណោះរួច ខ្ញុំហើយនិង លីន ក៏បែកគ្នាទៅកន្លែងរៀងៗខ្លួន ។ ក្រោយពីស្ដាប់សេរីភាព ហើយខ្ញុំក៏ចាប់ផ្ដើមធ្វើសកម្មភាពប្រឆាំងបដិវត្តន៍តែម្តង ពេលកម្មាភិបាលចាត់តាំងអោយខ្ញុំភ្ជួរដី ខ្ញុំធ្វើអោយបាក់នង្គ័លអស់ ៥ ដោយយុទ្ធវិធីភ្ជួរបំបុកគល់ឈើ ភ្ជួរដីធ្វើអោយវែងជាប្រចាំថ្ងៃ បំផុសគេឯងអ្នកភ្ជួរដូចគ្នាអោយខ្ជិលធ្វើការងារ អោយដើរបេះក្រូចថ្លុងលើប៉ុសេ រហូតអត់ធ្វើការងារទៀតក៏បាន . ហើយបំផុសមិត្តយើងនៅក្នុងអង្គភាពអោយដើរលេងទាក់ទងប្រជាជនរកគ្រឿងហូប ដើម្បីធ្វើអោយខូចឥទ្ធិពល ដោយព្រាយរវាងកងទ័ពនិងប្រជាជន ក្រោយមកទៀតខ្ញុំបាននាំមិត្តយើងទៅលួចផលដំណាំរបស់អង្គភាពគេ ដើម្បីធ្វើអោយទំនាស់គ្នាជាមួយអង្គភាពគេជាបន្តបន្ទាប់ រហូតបំផុសមិត្តយើងនៅក្នុងអង្គភាពអោយស៊ីខ្យង.ក្លាយទៅជាបន្តបន្ទាប់ រហូតមិត្តខ្លះហូបទៅបណ្តាល

ដោយយឺតទាតការងារបដិវត្តន៍ បន្ទាប់ពីនេះខ្ញុំបានលួចព្រត្តិស្បៀងគោយក បករស្វារអស់មួយចំនួន លួចបាយ លួចដំឡូង លួចដាក់ទឹកត្នោតផឹកដោយគ្មានការ ចាត់តាំង លួចអង្ករដាំបាយហូបឯកជន លួចអង្រឹងយកទៅដូរសម្ភារៈជាមួយ ប្រជាជន លួចឈើក្រខ្ទូររបស់អង្គភាពគេ ធ្វើអោយទំនាស់ពីអង្គភាពមួយ ទៅអង្គភាពមួយជាបន្តបន្ទាប់ជាប់មិនដាច់ទេ ។ រហូតមកដល់ខែ១១.៧៦ រយៈនេះអង្គភាពដែលខ្ញុំរស់នៅត្រូវមានភារៈកិច្ចថែទាំស្រូវ ដោយខែច្រូត រួចខ្ញុំផ្ទាល់ ពេលកម្មាភិបាលចាត់តាំងរូបខ្ញុំអោយទៅដេញចាប ខ្ញុំមិន ដេញទេគិតតែដើរកកេះកកោះស៊ី ធ្វើអោយចាបស៊ីស្រូវអស់មួយចំនួន និងលួចកាត់កន្ទួរលើងហូបជាបន្តបន្ទាប់ រហូតមកដល់ពាក់កណ្ដាលខែ១១.៧៦ អង្គការបានដករូបខ្ញុំពីដេញចាបអោយមកធ្វើជីរ ពេលនោះអង្គការបាន ដាក់ផែនការអោយធ្វើជីរក្នុងមួយថ្ងៃអោយបានបួនធុង តែចំពោះរូបខ្ញុំ ធ្វើមិនបានតាមផែនការរបស់បក្សទេ សេរីមិនស្ដាប់ការណែនាំរបស់កម្មាភិបាល ក្រោយមកទៀតកម្មាភិបាលចាត់តាំងរូបខ្ញុំនិងមិត្តយើងមួយចំនួនទៀតអោយ ទៅសីកឈើនៅទួលគោយកមកធ្វើរោងជីរ ពេលទៅដល់ហើយខ្ញុំមិនរួតរះ នាំគ្នាដាក់ឈើយកមកវិញទេ គឺបបួលគ្នាលួចបេះផ្លូងទៅវិញៗ ចូលមកដល់ ខែ១២.៧៦ ខ្ញុំក៏មានជម្ងឺទៅដេកពេទ្យអស់រយៈកន្លះខែ ទើបខ្ញុំជាសះ ស្បើយ ហើយខ្ញុំក៏ត្រឡប់មកអង្គភាពវិញ ពេលនោះនៅពាក់កណ្ដាល

ខែ១២.៧៦ ឈ្មោះ ឃុន បានចាត់តាំងរូបខ្ញុំអោយទៅនៅមន្ទីរវរៈសេនាធំ
១២ វិញ ក្នុងនោះមានឈ្មោះ រាល្ល ឈ្មោះ ឯម ជាអ្នកទទួលខុសត្រូវ
នាទីគាត់ជាប្រធានមន្ទីរវរៈសេនាធំ១២ បច្ចុប្បន្នអង្គការចាប់ឈ្មោះ
រាល្ល បាត់ហើយ នៅតែឈ្មោះ ឯម ទេគឺសព្វថ្ងៃនៅអង្គភាពវរៈសេនា
តូច៣១៧ ។ ក្រោយពីខ្ញុំបានទៅរស់នៅមន្ទីរនេះភ្លាមគឺខ្ញុំមិនហ៊ាន
ធ្វើសកម្មភាពទេ គឺត្រូវផ្អាកមួយរយៈសិនពីព្រោះខ្ញុំមិនស្គាល់គេ រហូតដល់
ខែ១១.៧៧ អង្គការបានចាត់តាំងរូបខ្ញុំអោយទៅដាំបាយនៅមន្ទីរវរៈសេ
នាធំ១២ ពេលនោះខ្ញុំត្រូវជួបខ្សែរបក្សពួករបស់ខ្ញុំគឺឈ្មោះ សឺន ហើយក៏ចាប់
ទាក់ទងគ្នា ដើម្បីពិភាក្សារគ្នាក្នុងការធ្វើសកម្មភាព តែក្នុងការ
ទាក់ទងនេះគឺមិនបានយូរទេ គ្រាន់តែ សឺន ពង្រឹងសកម្មភាពរបស់ខ្ញុំតទៅ
ទៀត ហើយត្រូវលក្ខការអោយជិត ។ ក្រោយពីបានជួបគ្នាជាមួយ
ឈ្មោះ សឺន ខ្ញុំក៏ចាប់ផ្តើមធ្វើសកម្មភាពតទៅទៀតដែរ ខ្ញុំដាំបាយធ្វើ
អោយឆៅ ស្លរមិនឈាងបន្លែជាបន្តបន្ទាប់ លួចលាក់បាយទុកហូបយប់ជាប្រចាំ
រហូតដល់ខែ១២.៧៧ ឈ្មោះ ឯម ចាត់តាំងរូបខ្ញុំអោយមកស្លរថ្នាំម្តង តែ
ពេលនោះខ្ញុំមិនបានស្លរទេ គឺកម្មាភិបាលនៅក្នុងនោះចាត់តាំងរូបខ្ញុំអោយ
ដាំបន្លែវិញ ពេលបន្លែដាំដុះរស់ហើយខ្ញុំមិនស្រោចទឹកទុកអោយបន្លែ
នេះងាប់ជាបន្តបន្ទាប់ ពេលធ្វើការងារឈ្លៀតឱកាសដើរទាក់ទង

ប្រជាជនកែនេះកែនោះយកមកធ្វើជាញាតិញាយ ក្រោយមកកម្មាភិបាល
ចាត់តាំងអោយរាយសន្ទូច ពេលនោះខ្ញុំរាយបានត្រីហើយមិនយកអោយសេ
ដ្ឋកិច្ចទាំងអស់ទេ គឺខ្ញុំលាក់ទុកខ្លះដើម្បីសុំស្ញូបងកជន លួចធ្វើទឹកត្រោតជូរ
ផឹកជាបន្តបន្ទាប់ រហូតមកដល់ខែ១៣.៧៧ ឈ្មោះទាល្ល បានចាត់តាំងរូបខ្ញុំ
អោយមកនៅទួលឈរ័ង្គរនៅជាមួយកងពិការ វេះនោះខ្ញុំមិនហ៊ានធ្វើ
សកម្មភាពទេ គឺត្រូវផ្អាកមួយរយៈសិន ដោយពេលនោះអង្គការកំពុងចាប់
មេដឹកនាំក្បត់របស់ខ្ញុំទៅបាត់ ដូច្នេះសកម្មភាពរបស់ខ្ញុំត្រូវផ្អាករហូតដល់
ខែ០៦.៧៧ អង្គការក៏បានចាប់តាំងរូបខ្ញុំអោយមកនៅក្នុងអង្គភាពវរៈសេនា
តូច ៣១៦ ក្នុងនោះមាន ឈ្មោះ ស៊ែន ជាអ្នកទទួលខុសត្រូវរួមក្នុងវរៈសេ
នាតូចនេះ បច្ចុប្បន្នអង្គការចាប់ ។ ក្រោយពីខ្ញុំចូលមកនៅអង្គភាព
វរៈសេនាតូចនេះហើយ ខ្ញុំបានធ្វើសកម្មភាពជាបន្តបន្ទាប់ នៅពេលកម្មា
ភិបាលចាត់តាំងអោយបាចទឹកបញ្ចូលស្រែ ខ្ញុំមិនបាចទឹកដាក់ទេទុកអោយស្រូវ
ងាប់បន្តបន្ទាប់ ពេលយប់កម្មាភិបាលចាត់តាំងអោយទៅដេញកណ្តុរ ខ្ញុំមិន
ដេញទេគិតតែដេករហូតដល់ម៉ោងគេសំរាក ទើបបានខ្ញុំមកជាមួយមិត្តយើង
មកកន្លែងវិញដែរ ។ ចូលមកដល់ខែ ៧.៧៧ ខ្ញុំត្រូវមានភារៈកិច្ចថែ
ទាំស្រូវដដែល ពេលកម្មាភិបាលចាត់តាំងអោយដេញចាប ពេលនោះ
ខ្ញុំមិនដេញទេ គិតតែដេកទាំងព្រឹកទាំងល្ងាចជាប្រចាំ រហូតដល់ពាក់

កណ្តាលខែ១៧.៧៧ ខ្ញុំបានទាក់ទងជាមួយឈ្មោះ លិន ដែលជាមេក្រុមក្រុក របស់ សឹន ចាស់ ដើម្បីពិគ្រោះគ្នាក្នុងការធ្វើសកម្មភាពតទៅមុខទៀត ពេលនោះ លិន បានស្នាក់ផែនការអោយខ្ញុំអនុវត្តន៍ គឺត្រូវបំផ្លាញផលប្រយោជន៍បដិវត្តន៍បន្តទៅទៀត ហើយនិងសម្ភារៈពាំងពីតូចរហូតដល់ធំ ហើយត្រូវបំផុសគេឯងទៅក្នុងអង្គភាពអោយស៊ីផ្លែឈើរាពុល ដើម្បីធ្វើអោយខូចខាតកម្លាំងបដិវត្តន៍ ពេលនោះ លិន បានលើកពាក្យស្លោកមួយអោយខ្ញុំដើរនិយាយថា " ធ្វើស្រែនិងទឹកភ្លៀងស៊ីបាយ " ធ្វើស្រែនិងប្រឡាយស៊ីត្រកួននិងប្រហើត " ក្រៅពីនេះទៀតយើងត្រូវបំផុសមិត្តយើងនៅក្នុងអង្គភាពអោយខ្ជិលធ្វើការងារទៀត ។ ក្រោយពីពិគ្រោះគ្នាអស់រយៈមួយម៉ោងមកខ្ញុំនិង លិន ក៏បែកគ្នាទៅ ចំពោះផែនការរបស់ លិន ខ្ញុំមិនបានសរេចតាមទាំងអស់ទេ គឺខ្ញុំធ្វើបានមួយចំនួនប៉ុណ្ណោះ ។ ពេលធ្វើដីស្ទូងខ្ញុំធ្វើមិនអោយស្មើរ ដកសំណាបធ្វើអោយដាច់ដាបន្តបន្ទាប់ ទីរកសំណាបធ្វើអោយប្រផុះហើយមិនរើស ស្ទូងធ្វើអោយបទគល់បណ្តោយអោយរវែណ្ត ស្ទូងមិនតាមផែនការរបស់បក្ស ស្ទូងរាងៀលៗ ក្រៅពីនេះទៀតខ្ញុំបានបំផ្លាញសម្ភារៈកសិកម្មអស់មួយចំនួនដូចជា ចប.កាំបិត. ជាដើម ។ ដោយយកទុកវិធី ធ្វើអោយបាក់ហើយនិងបាត់ ។

សារុបមក: ខ្ញុំធ្វើសកម្មភាពខូចខាងលើនេះរហូតដល់ខែ១០.៧៧ ក្រោយ

ពីខ្ញុំធ្វើសកម្មភាពនេះ    ហើយខ្ញុំបានបំផុសមិត្តយើងនៅក្នុងអង្គភាពកោយស៊ីវ៉ែ
លចំណែកខ្មាចពុលស្លាប់អស់ចំនួន ៧ នាក់ ហើយក្លួចបង្ការ ៣ នាក់តែមិន
ស្លាប់ទេ   ក្រោយពីខ្ញុំធ្វើសកម្មភាពដូចនេះហើយរហូតមកដល់ថ្ងៃទី៦.១១.៧៧
អង្គការចាប់រូបខ្ញុំមកកន្លែងនេះតែម្ដង ។

o

o o

ធ្វើនៅថ្ងៃទី ២៨ ខែ ១១ ឆ្នាំ ១៩៧៧

ខ្ញុំឈ្មោះ ចាន់ . ទ្រុង ជាអ្នកសារភាព